# ខិត្តប័ណ្ណព័ត៌មាន - ដីកាសុវត្ថិភាពសហគមន៍សាលារៀនជាបន្ទាន់

## តើដីកាសុវត្ថិភាពសហគមន៍សាលារៀនជាបន្ទាន់បំពេញមុខការអ្វីខ្លះ?

មនុស្សមួយចំនួនដូចជានាយកសាលា និងបុគ្គលិកក្រសួងអប់រំ និងបណ្តុះបណ្តាល ត្រូវបានគេហៅថា "បុគ្គលដែលមានសិទ្ធិអំណាច"។
ពួកគេមានអំណាចក្នុងការចេញដីកាដែលកំណត់ច្បាប់ទំលាប់នានាដើម្បីឱ្យអ្នកអនុលោមតាម នៅពេលអ្នកទៅ ឬទាក់ទិនជាមួយសាលារៀន។

ដីកាអាចបញ្ឈប់អ្នកពីការចូល ឬស្នាក់នៅក្នុងបរិវេណសាលា ឬកន្លែងផ្សេងទៀតដែលសកម្មភាពសាលារៀនកើតឡើង។
ដីកាអាចរួមបញ្ចូលព័ត៌មានលម្អិតនានាដូចជាពេលវេលា ឬផ្នែកផ្សេងទៀតដែលមិនមានក្នុងដីកា។

ព័ត៌មានបន្ថែមអំពីដីកាសុវត្ថិភាពសហគមន៍សាលារៀនអាចរកបាននៅទីនេះ។
អ្នកអាចមើលវីដេអូនៅទីនេះ ដើម្បីជួយអ្នកឱ្យយល់ដឹងពីអ្វីដែលដីកាសុវត្ថិភាពសហគមន៍សាលារៀនធ្វើ។

## តើដីកាជាបន្ទាន់ត្រូវបានដាក់ដំណើរការរយៈពេលប៉ុន្មាន?

ដីកាក៏ប្រាប់អ្នកផងដែរពីរយៈពេលដែលច្បាប់ទំលាប់ទាំងនេះនឹងត្រូវបានដាក់ដំណើរការ។
រយៈពេលវែងបំផុតដែលដីកាអាចត្រូវបានដាក់ដំណើរការគឺ 14 ថ្ងៃ។

## ប្រសិនបើខ្ញុំមានកូននៅសាលារៀន តើនឹងមានអ្វីកើតឡើងចំពោះពួកគេឥឡូវនេះ ដែលខ្ញុំត្រូវតែអនុលោមតាមដីកាភ្លាមៗ?

សាលារៀនរបស់អ្នកបានគិតដោយប្រុងប្រយ័ត្ន អំពីរបៀបដែលដីកានឹងប៉ះពាល់ដល់កូនរបស់អ្នក និងរបៀបដែលអ្នកថែទាំពួកគេ។ ដីកាមិនមានន័យ បញ្ឈប់អ្នកពីការថែទាំពួកគេ ឬពាក់ព័ន្ធនឹងការអប់រំរបស់ពួកគេនោះទេ។

សាលារៀនរបស់អ្នកនឹងផ្តល់ឱ្យអ្នកនូវ 'ពិធីការទំនាក់ទំនង និងការចូលប្រើប្រាស់ ' ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីប្រគល់ដីកាជូនអ្នក។ នេះនឹងកំណត់ពីៈ

- របៀបដែលអ្នកអាចត្រូវបានគេប្រាប់អំពីការអប់រំរបស់កូនអ្នក
- របៀបដែលកូនរបស់អ្នកអាចបន្តទៅសាលារៀន និងចូលរួមក្នុងសកម្មភាពសាលារៀនដោយសុវត្ថិភាព
- អ្វីដែលពួកគេនឹងធ្វើដើម្បីធ្វើឱ្យប្រាកដថា កូនរបស់អ្នកត្រូវបានគាំទ្រ និងថែទាំ។

## ចុះបើខ្ញុំមិនយល់ស្របជាមួយនឹងដីកាជាបន្ទាន់?

បុគ្គលដែលមានសិទ្ធិអំណាចដែលបានធ្វើដីកា ត្រូវតែពិនិត្យដីកាភ្លាមៗបន្ទាប់ពីពួកគេបានធ្វើវា ដើម្បីពិចារណាថា តើពួកគេគួរតែធ្វើ 'ដីកាសុវត្ថិភាពសហគមន៍សាលារៀនដែលកំពុងដំណើរការ' ឬក៏លុបចោលដីកានោះ។
ព័ត៌មានបន្ថែមអំពីដីកាដែលកំពុងដំណើរការអាចរកបាននៅលើគេហទំព័ររបស់ក្រសួងអប់រំ និងបណ្តុះបណ្តាលនៅទីនេះ។

THE EDUCATION STATE

VICTORIA State Government | Education and Training

អ្នកអាចធ្វើ 'ការដាក់ស្នើ' នៅពេលណាក៏បាន ដើម្បីពន្យល់ពីហេតុផលដែលអ្នកបានប្រព្រឹត្តក្នុងវិធីជាក់លាក់មួយ វិធីដែលវានឹងប៉ះពាល់ដល់អ្នក ឬកូនរបស់អ្នក ឬអ្វីផ្សេងទៀតដែលពួកគេត្រូវការដឹង។ ឧទាហរណ៍ អ្នកប្រហែលជាចង់ប្រាប់សាលារៀនថា កូនរបស់អ្នកមានពិការភាព ដើម្បីឱ្យពួកគេអាចប្រាកដថា អ្នកអាចបន្តគាំទ្រពួកគេឱ្យទៅសាលារៀនបាន។

ការដាក់ស្នើជាលាយលក្ខណ៍អក្សរអាចធ្វើឡើងជាអ៊ីមែល ឬលិខិតទៅកាន់បុគ្គលដែលមានសិទ្ធិអំណាច។ អ្នកអាចប្រើគំរូនៅលើគេហទំព័ររបស់ក្រសួងអប់រំ និងបណ្តុះបណ្តាលនៅទីនេះ។

ប្រសិនបើអ្នកមិនចង់សរសេរការដាក់ស្នើទេ អ្នកអាចស្នើសុំឱ្យដាក់ជាពាក្យសំដីជំនួសវិញ។ អ្នកក៏អាចស្នើសុំឱ្យអ្នកផ្សេងធ្វើការដាក់ស្នើជូនអ្នកផងដែរ ដូចជាបុគ្គលគាំទ្រពិការភាពរបស់អ្នក ឬអ្នកបកប្រែភាសាផ្ទាល់មាត់ជាដើម។

**តើមានអ្វីកើតឡើងប្រសិនបើខ្ញុំមិនអនុលោមតាមដីកា?**

ប្រសិនបើអ្នកមិនអនុលោមតាមច្បាប់ទំលាប់នានាដែលមានចែងក្នុងដីកាទេ សាលារៀនអាចដាក់ពាក្យទៅតុលាការដំបូង (Magistrate’s Court) ដើម្បីបង្ខំអ្នកឱ្យអនុលោមតាមដីកានោះ។

ប្រសិនបើតុលាការដំបូងរកឃើញថា អ្នកខុសដោយមិនអនុលោមតាមដីកា ពួកគេអាច៖

- តម្រូវឱ្យអ្នកបង់ប្រាក់ពិន័យ
- តម្រូវឱ្យអ្នកអនុលោមតាមដីកា
- តម្រូវឱ្យអ្នកចាត់វិធានការជាក់លាក់ ដើម្បីអនុលោមតាមដីកា
- តម្រូវឱ្យអ្នកធ្វើអ្វីផ្សេងទៀតដែលតុលាការគិតថាសមស្រប។

អ្នកនឹងមិនត្រូវជាប់ពន្ធនាគារ មិនជាប់ក្នុងកំណត់ត្រាបទឧក្រិដ្ឋ ឬពុំមានការពិន័យបទឧក្រិដ្ឋចំពោះការមិនអនុលោមតាមដីកាទេ។

## ចុះបើខ្ញុំត្រូវការអ្នកបកប្រែភាសាសរសេរ/អ្នកបកប្រែភាសាផ្ទាល់មាត់ ឬជំនួយផ្សេងទៀត?

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាសរសេរ អ្នកបកប្រែភាសាផ្ទាល់មាត់ ឬអ្នកគាំទ្រ អ្នកអាចប្រាប់នាយកសាលាដែលអាចជួយអ្នកទទួលបានការគាំទ្រ។

ប្រសិនបើកូនរបស់អ្នកទៅសាលារៀនរដ្ឋ អ្នកក៏អាចទាក់ទងការិយាល័យប្រចាំតំបន់របស់ក្រសួងអប់រំ និងបណ្តុះបណ្តាលសម្រាប់ជំនួយបន្ថែមផងដែរ។

| | |
|---|---|
| តំបន់ខាងជើងឆៀងខាងកើតរដ្ឋវិចថូរៀ<br>ទូរសព្ទ៖ 1300 333 231<br>អ៊ីមែល៖ nevr@education.vic.gov.au | តំបន់ខាងជើងឆៀងខាងលិចរដ្ឋវិចថូរៀ<br>ទូរសព្ទ៖ 1300 338 691<br>អ៊ីមែល៖ nwvr@education.vic.gov.au |
| តំបន់ខាងត្បូងឆៀងខាងកើតរដ្ឋវិចថូរៀ<br>អ៊ីមែល៖ 1300 338 738<br>អ៊ីមែល៖ sevr@education.vic.gov.au | តំបន់ខាងត្បូងឆៀងខាងលិចរដ្ឋវិចថូរៀ<br>ទូរសព្ទ៖ 1300 333 232<br>អ៊ីមែល៖ swvr@education.vic.gov.au |

## ចុះបើខ្ញុំចង់បានព័ត៌មានបន្ថែមទៀត?

អ្នកអាចចូលទៅកាន់គេហទំព័ររបស់ក្រសួងអប់រំ និងបណ្តុះបណ្តាលនៅទីនេះ សម្រាប់ព័ត៌មានបន្ថែម។